ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ៣៨ ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

—ក—

មាតិកា

I- ទីស្តីការគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

១៦.១០.៩៥	– អនុក្រឹត្យលេខ ៨០. អនក្រ.បក ស្តីពីការបន្ថែមសមាជិកនៅក្នុងសមាសភាព នៃគណៈកម្មការបច្ចេកទេសអន្តរក្រសួងសំរាប់ការរុករក និង អាជីវកម្មប្រេងកាត	១៩៦៧
១៩.១០.៩៥	– អនុក្រឹត្យលេខ ១១៤. អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១៩៦៨
១៩.១០.៩៥	– អនុក្រឹត្យលេខ ១១៥. អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១៩៧០
១៩.១០.៩៥	– អនុក្រឹត្យលេខ ១១៦. អនក្រ.តត ស្តីពីការដាក់មន្ត្រី រាជការស៊ីវិលអោយស្ថិតនៅក្នុងភាពទំនេរ គ្មានបៀវត្ស	១៩៧១
១៩.១០.០៥	– អនុក្រឹត្យលេខ ១១៧ អនក្រ.តត ស្តីពីការតែងតាំងមុខតំណែង	១៩៧៤

២.សេចក្តីសំរេច

១៦.១០.៩៥	– សេចក្តីសំរេចលេខ ៧៣ សសរ ស្តីពីការកែសំរួលកំពូក ២ នៃបទបញ្ញត្តិប្រេងកាតកម្ពុជា ឆ្នាំ ១៩៩១	១៩៧៥
១៦.១០.៩៥	– សេចក្តីសំរេចលេខ ៧៤ សសរ ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន	១៩៧៨
១៦.១០.៩៥	– សេចក្តីសំរេចលេខ ៧៥ សសរ ស្តីពីការផ្ទេរសិទ្ធិ	១៩៧៩
១៦.១០.៩៥	– សេចក្តីសំរេចលេខ ៧៥ ស្ទួន សសរ ស្តីពីការផ្ទេរភារកិច្ចដឹកនាំការងារ	១៩៨០

១៧.១០.៩៥ – សេចក្ដីសំរេចលេខ ៧៦ សសរ ស្ដីពីការត្រៀមចូលរួមក្នុងកិច្ចប្រជុំលើកទី [illegible] នៃក្រុមពិគ្រោះយោបល់ (First Consultative Group Meeting) ១៩៨១

៣— សេចក្ដីជូនដំណឹង

១៧.១០.៩៥ – សេចក្ដីសំរេចលេខ ៧៦ សជណ.សរ សេចក្ដីថ្លែងហេតុ សេចក្ដីព្រាងច្បាប់ ស្ដីពីការការពារបេតិកភ័ណ្ឌវប្បធម៌ ១៩៨៣

II- ការងាររបស់ក្រសួង

១—ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

១៦.១០.៩៥ ប្រកាសលេខ ៣៣៧ ប្រក.សហវ.ថ ស្ដីពីការបែងចែកឥណទាន ១៩៨៥

២—ទីស្ដីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

១៧.១០.៩៥ ប្រកាសលេខ ២៦០/៩៥ ពម.ប្រក ស្ដីពីការយល់ព្រមផ្ទេរសិទ្ធិពីលោក ភោគ សុគន្ធ ជាងហ្វាងការផ្សាយសារពត៌មាន « សាធារណរដ្ឋ » មកលោក លឹម រតនា វិញ ១៩៨៧

១៨.១០.៩៥ ប្រកាសលេខ ២៦១/៩៥ ពម.ប្រក អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅ[illegible] និង ផ្ទាំងរូបភាពបន្ថែម ដោយមាន លោក KOJI [illegible] ប្រធាន [illegible] នៃអង្គការជំនួយស្ម័គ្រចិត្ត ជប៉ុន ជាអ្នកទទួលខុសត្រូវ ១៩៨៨

២០.១០.៩៥ ប្រកាសលេខ ២៦៤ ពម.ប្រក ស្ដីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌក្រសួង ១៩៨៩

[illegible].១០.៩៥ ប្រកាសលេខ ២៦៥ ពម.ប្រក អនុញ្ញាតអោយដំណើរការបោះពុម្ពផ្សាយ[illegible] « សញ្ញារះរាត្រី » ១៩៩១

២០.១០.៩៥ ប្រកាសលេខ ២៦៦ ពម.ប្រក ស្តីពីការអនុញ្ញាតអោយកាសែត CAMBODGE SOIR ប្តូរឈ្មោះនិពន្ធនាយកពីលោក PHILIPPE LATOUR ជូនមកលោក PIRRE GILLETTE វិញ ១៩៩២

២០.១០.៩៥ ប្រកាសលេខ ២៦៧ ពម.ប្រក ស្តីពីការយល់ព្រម និង ទទួលស្គាល់មន្ត្រីពជការ ១៩៩៣

៣—ទីស្តីការរដ្ឋមន្ត្រីក្រសួង សាធារណការ និងដឹកជញ្ជូន

សេចក្តីសំរេច

១៩.១០.៩៥ សេចក្តីសំរេចលេខ ០៤៦ សសរស.ក ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីពិនិត្យវាយតម្លៃលើសម្បត្តិអចល័តគ្មានលទ្ធភាពជួសជុលរបស់រាជាយស្វ័យយានកម្ពុជា ១៩៩៤

៤—ទីស្តីការរដ្ឋមន្ត្រីក្រសួង ផែនការ

ប្រកាស

១៧.១០.៩៥ ប្រកាសលេខ ០៦ ប្រផក ស្តីពីលទ្ធផលប្រឡងបញ្ចប់ការសិក្សាផ្នែកជំនាញស្ថិតិសេដ្ឋកិច្ចជំនាន់ទី VI ១៩៩៦

៥—ទីស្តីការក្រសួងធម្មការ និង សាសនា

ប្រកាស

១៦.១០.៩៥ ប្រកាសលេខ ២២៤/៩៥ កធស.ប្រក ស្តីពីការយល់ព្រមទទួលស្គាល់មន្ត្រីពជការ ១៩៩៧

១៦.១០.៩៥	ប្រកាសលេខ ២២៥/៩៥ កធស. ប្រក ស្តីពីការទទួលស្គាល់ជាផ្លូវការរចនាសម្ព័ន្ធ និង ក្របខ័ណ្ឌមន្ត្រីធម្មការ និង សាសនា ខេត្តតាកែវ	១៩៩៩
១៦.១០.៩៥	ប្រកាសលេខ ២២៦/៩៥ កធស. ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ	២០០១

៦—ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

១៩.១០.៩៥	ប្រកាសលេខ ១៦៧៩ អយក. ប្រក ស្តីពីការបើកអនុវិទ្យាល័យសម្តេច ហ៊ុន សែន ក្នុងឃុំនាម ស្រុកទ្រាំង ខេត្តតាកែវ	២០០២
១៩.១០.៩៥	ប្រកាសលេខ ១៦៧៣ អយក. ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ តរ ក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម ទៅជាអនុវិទ្យាល័យសម្តេច ហ៊ុន សែន	២០០៤
១៩.១០.៩៥	ប្រកាសលេខ ១៦៧៤ អយក. ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ ព្រែកដំបង នៅក្នុងស្រុក មុខកំពូល ខេត្តកណ្តាល ទៅជាអនុវិទ្យាល័យសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ	២០០៥
១៩.១០.៩៥	ប្រកាសលេខ ១៦៧៥ អយក. ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ កោខ្នុរ ក្នុងឃុំកោខ្នុរ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាមទៅជាអនុវិទ្យាល័យសម្តេច ហ៊ុន សែន	២០០៦
១៩.១០.៩៥	ប្រកាសលេខ ១៦៧៦ អយក. ប្រក ស្តីពីការបើកវិទ្យាល័យបានលុង នៅខេត្ត រតនគិរី	២០០៧

៧—ទីស្តីការក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

១៨.១០.៩៥ ប្រកាសលេខ ១៧០ ប្រក.វវស.ប្ ស្ដីពីការលុបឈ្មោះមន្ត្រីរាជការ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តកំពង់ឆ្នាំង ២០០៨

១៨.១០.៩៥ ប្រកាសលេខ ១៧១ ប្រក.វវស.ប្ ស្ដីពីការផ្លាស់ប្ដូរកន្លែងធ្វើការរបស់មន្ត្រីរាជការ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈរាជធានីភ្នំពេញ ២០០៩

៨—រដ្ឋលេខាធិការដ្ឋាន

មុខងារសាធារណៈ

ប្រកាស

២១.១០.៩៥ សេចក្ដីសំរេចលេខ ១០៧៩ សសរ.មស.ប្រខ ស្ដីពីការបែងចែកសិស្សនិស្សិត ចំនួន ៩៧ នាក់ ដែលទើបបញ្ចប់ការសិក្សាពីក្រៅប្រទេស ២០១០

I - ឯកសារគណៈរដ្ឋមន្ត្រី

១— អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៤០ អនក្រ.បក

ស្តីពីការបន្ថែមសមាជិកនៅក្នុងសមាសភាពនៃគណៈកម្មការ

បច្ចេកទេសអន្តរក្រសួងសំរាប់កិច្ចការរុករកនិងអាជីវកម្មប្រេងកាត

* * *

រាជរដ្ឋាភិបាលកម្ពុជា

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

–បានឃើញអនុក្រឹត្យលេខ ៣៣ អនក្រ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល

–យោងតាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : បន្ថែមសមាជិក ០២ រូប នៅក្នុងសមាសភាពនៃគណៈកម្មការបច្ចេកទេសអន្តរក្រសួងសំរាប់កិច្ចការរុករក និង អាជីវកម្មប្រេងកាត ដែលមានចែងក្នុងមាត្រា ១ នៃ អនុក្រឹត្យលេខ ៣៣ អនក្រ. ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាលមានដូច តទៅ ÷

១–ឯកឧត្តម **ឈាង ឆាន់** អគ្គលេខាធិការរាជរដ្ឋាភិបាល សមាជិក

២-ឯកឧត្តម អ៊ិត ប្រាំង រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែនិងថាមពលគណៈកម្មការបច្ចេកទេសអន្តរក្រសួង សំរាប់កិច្ចការរុករក និង អាជីវកម្មប្រេងកាត ក្រសួងស្ថាប័ន ខេត្តក្រុងពាក់ព័ន្ធ និង សាមីខ្លួន ដែរមានចែងក្នុងមាត្រា ១ ត្រូវទទួល អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១
ព្រះហស្តលេខានិងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី២
ហត្ថលេខានិងត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១១៤ អនក្រ.តត
ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនា ជាតិ
- តាមសំណើរបស់ក្រសួងធម្មការ និងសាសនា

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ចំពោះសប្បុរសជនដែលបានជួយកសាងកុដិលើឈើ វត្តឈរសមន្ត្រី សាលាភត្តកុដិ សាលាធម៌ សាលាបឋមសិក្សាវត្តឈរសមន្ត្រី ឃុំព្រៃភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត ។

សប្បុរសជនទាំងនេះមានឈ្មោះដូចខាងក្រោម ÷

ក–មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ចំពោះ ÷

១–លោក **សរ ជីន** និងអ្នកស្រី **ម៉ែន ឃុន** ជនជាតិខ្មែរនៅសហរដ្ឋអាមេរិក ឧបត្ថម្ភប្រាក់ ១០.៧១២ ដុល្លារអាមេរិក

២–លោក **គង់ ម៉ែត** និងអ្នកស្រី **ឡុយ គឹមសេង** ជនជាតិខ្មែរនៅសហរដ្ឋអាមេរិក ឧបត្ថម្ភប្រាក់ ១០.៨១០ ដុល្លារអាមេរិក

ខ–មេដាយស្ថាបនាជាតិថ្នាក់លេខ ៣ ចំពោះ ÷

១–ព្រះតេជគុណ **សារ សារុន្ត** ព្រះសង្ឃខ្មែរនៅប្រទេសបារាំង ឧបត្ថម្ភបច្ច័យ ១.៨៥០ ដុល្លារអាមេរិក

២–លោក **ជុំ ឈឹម** ជនជាតិខ្មែរនៅសហរដ្ឋអាមេរិក ឧបត្ថម្ភប្រាក់ ១.០០០ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១១៥ អនក្រ .តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់ក្រសួងធម្មការ និង សាសនា

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ថ្នាក់លេខ ១ ចំពោះសាសនិកជប៉ុន ដែលជួយបន្ត បោះពុម្ពសៀវភៅពុទ្ធសាសនា ក្នុងគោលបំណងពង្រឹងពង្រីកវិស័យព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា សាសនិកជប៉ុន មានមួយក្រុមនិងលោក៤រូប ដូចមាន តាមខាងក្រោម ៖

១- COMMUNITY SALONSEI RAN

២- MR KOUSAKU NOGUCHI

៣- MR TAKESHI TSUZURANUKI

៤- MS TSUTAE KOYATA

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងក្រសួងធម្មការ និង សាសនាត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១១៦ អនក្រ.តត
ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលអោយស្ថិតនៅក្នុងភាពទំនេរ គ្មានបៀវត្ស

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៩០ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦ នស.៩៤.ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- តាមសំណើ របស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

សំរេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា ១ : ភាពទំនេរគ្មានបៀវត្ស គឺជាស្ថានភាពរបស់មន្ត្រីរាជការ ដែលបាត់សិទ្ធិទទួលប្រាក់បៀវត្ស ព្រមទាំងបាត់សិទ្ធិឡើងថ្នាក់និងអតីតភាពការងារសំរាប់ទទួលសោធននិវត្តន៍ ។

មាត្រា ២ : ភាពទំនេរគ្មានបៀវត្សត្រូវប្រកាសដោយ បញ្ញត្តិ ឬ ត្រូវបានអនុញ្ញាតដោយស្ថាប័នមានសមត្ថកិច្ចក្នុងការតែងតាំងតាមពាក្យ ស្នើសុំរបស់សាមីជន ។

ការដាក់មន្ត្រីរាជការអោយស្ថិតនៅក្នុងភាពទំនេរ គ្មានបៀវត្សត្រូវសំរេចដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាស ។

ជំពូកទី២

ភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ

មាត្រា ៣ : ការដាក់មន្ត្រីរាជការអោយស្ថិតនៅក្នុងភាពទំនេរ គ្មានបៀវត្សដោយបញ្ញត្តិមានករណីដូចតទៅ :

–មន្ត្រីរាជការដែលបោះបង់ការងារ ឬ អវត្តមានដោយគ្មានច្បាប់អនុញ្ញាតរយៈពេល ១៥ ថ្ងៃជាប់គ្នា លើកលែងតែមន្ត្រីនោះមានករណីពិសេសណាមួយ ។ ក្នុងពេលនោះពេល ១៥ ថ្ងៃដែលអវត្តមាននេះ ប្រធានស្ថាប័នត្រូវរំលឹកសាមីខ្លួន យ៉ាងហោចណាស់ពីរដងដែរ។

–មន្ត្រីរាជការស្ថិតក្នុងការជំនុំជំរះរបស់តុលាការថាមានទោសពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមហើយដែលបានផ្តន្ទាទោស រហូតដល់ថ្ងៃមានសាលាក្រមចុងក្រោយជាស្ថាពរ ។

មាត្រា ៤ : រយៈពេលនៃការដាក់អោយស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ ក្នុងករណី ដែលបានចែងនៅក្នុងកថាខណ្ឌទី២ នៃមាត្រា ៣ ខាងលើនេះពុំអាចលើសពី ៣ ខែឡើយ ។ ក្នុងរយៈពេល ៣ខែនេះ មន្ត្រីរាជការ ដែលពុំបានត្រឡប់ទៅបំពេញការងារ វិញក្រោយពីបានដាក់កំហិតអោយចូលធ្វើការតាមការកំណត់ពីរដង ត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌ តែនៅមានសិទ្ធិទទួលប្រាក់សោធននិវត្តន៍ ឬ ប្រាក់ [illegible] តាមអតីតភាពការងារ ។ [illegible]

[illegible]

ជំពូកទី៣

ភាពទំនេរគ្មានបៀវត្ស [illegible]

មាត្រា ៥ : ការដាក់អោយស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ត្រូវបានអនុញ្ញាតតាមពាក្យស្នើសុំរបស់សាមីខ្លួនលើកលែងតែមានការចាំបាច់របស់ក្រសួង ឬ ស្ថាប័ន ។ ភាពទំនេរគ្មានបៀវត្ស នេះមានរយៈពេលម្តងៗមិនតិចជាង ៦ ខែ និងមិនលើសពី **២ឆ្នាំ** ហើយអាចបន្តជាថ្មី សរុបទាំងអស់មិនអោយហួសពី ៤ ឆ្នាំ ។

ការដាក់អោយនៅទំនេរ គ្មានបៀវត្សនេះត្រូវអនុវត្តចំពោះករណីដូចខាងក្រោម :

- ដើម្បីអោយធ្វើការនៅក្នុងផ្នែកឯកជន ឬ ធ្វើការងារជាប្រយោជន៍សាធារណៈ ។
- ដើម្បីធ្វើការសិក្សានិងស្រាវជ្រាវនៅក្នុង ឬ ក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងទិសដៅដើម្បី ផលប្រយោជន៍ទូទៅ ។
- ដើម្បីបំពេញផលប្រយោជន៍ផ្ទាល់ខ្លួន ។

មាត្រា ៦ : ការដាក់អោយស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស **ត្រូវបានអនុញ្ញាតជាចាំបាច់ជូន** មន្ត្រីរាជការដែលបានដាក់ពាក្យស្នើសុំត្រឹមត្រូវតាមច្បាប់សំរាប់រយៈពេល **៣ខែ និង** មិនលើសពី ២ឆ្នាំហើយអាចបន្តជាថ្មីមិនអោយហួសពី ៤ ឆ្នាំ ចំពោះករណីដូចតទៅ :

- សុំទៅថែទាំសហព័ទ្ធ ឬ កូនដែលមានជំងឺធ្ងន់ ។
- សុំទៅរួមរស់ជាមួយសហព័ទ្ធ ជាមន្ត្រីរាជការក្នុងករណីសុំផ្លាស់មិនទាន់បាន ។

ជំពូកទី៤

[illegible] **និងការវិលចូលបំរើការងារវិញ**

មាត្រា ៧ : [illegible] ភាពទំនេរគ្មានបៀវត្ស តាមពាក្យស្នើសុំរបស់ មន្ត្រីរាជការមានប្រសិទ្ធភាពនៅថ្ងៃទី ០១ នៃខែបន្ទាប់ ដែលមានការយល់ព្រមពីថ្នាក់មានសមត្ថកិច្ចសំរេច ។

មាត្រា ៨ : មន្ត្រីរាជការស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ដោយមានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់ ត្រូវតែដាក់ពាក្យសុំបន្តភាពទំនេរគ្មានបៀវត្ស ឬចូលបំរើការងារវិញ យ៉ាងតិចមួយខែ មុនពេលផុតកំណត់ នៃរយៈពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ។ មន្ត្រីរាជការ ណាពុំបានដាក់ពាក្យសុំបន្តភាពទំនេរគ្មានបៀវត្ស ឬ ពុំបានចូលបំរើការងាររបស់ខ្លួនវិញ នៅថ្ងៃខួបក្រោយនៃភាពទំនេរគ្មានបៀវត្ស

ចាត់ទុកថាបោះបង់ចោលការងារ និងត្រូវបានលុបឈ្មោះពីក្របខ័ណ្ឌចាប់ពីថ្ងៃនោះតទៅ ។

មាត្រា ៩ : មន្ត្រីរាជការស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ដែលបានដាក់ពាក្យស្នើសុំច្បាប់ចូលបំរើការងារឡើងវិញនៅមុនពេលផុតកំណត់ ត្រូវស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរហូតដល់ ពេលណាមានកន្លែងទំនេរសំរាប់ធ្វើការវិញ ។

មាត្រា ១០ : ការចូលបំរើការងារវិញ គឺជាសិទ្ធិរបស់មន្ត្រីរាជការ ។ មន្ត្រីរាជការចូលបំរើការងារឡើងវិញមានអាទិភាពទទួលកន្លែងទំនេរសមស្រប និងឋានន្តរស័ក្តិរបស់ខ្លួន ។

មាត្រា ១១ : សេចក្តីសំរេចអោយចូលបំរើការងារឡើងវិញ ឬបញ្ឈប់ពីការងាររបស់មន្ត្រីរាជការស្ថិត នៅក្នុងភាពទំនេរគ្មានបៀវត្សត្រូវបានសំរេចដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាស ។

ជំពូកទី៥

អវសានបញ្ញត្តិ

មាត្រា ១២ : ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសដែលដាក់មន្ត្រីរាជការអោយស្ថិត នៅក្នុងភាពទំនេរគ្មាន បៀវត្សត្រូវធ្វើជាចាំបាច់ទៅ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈមួយច្បាប់ ។

មាត្រា ១៣ : បទបញ្ញត្តិ ទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ១៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួងរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១១៧ អនក្រ .គគ

ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ...

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និងអគ្គនាយកដ្ឋានកងទ័ពជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងការពារជាតិ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងមុខតំណែង អ្នកអង្គម្ចាស់ **ទី ថាវី** នាយករង នាយកដ្ឋានទាក់ទងអន្តរជាតិក្រសួងការពារជាតិ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានគាប់ពីថ្ងៃឡាយព្រះ ហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

២-- សេចក្តីសម្រេច.

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសម្រេចលេខ ៧៣ [illegible]

ស្តីពីការ[illegible]

[illegible] ឆ្នាំ ១៩៩៦

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ របស់ព្រះករុណា ព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-យោងព្រះរាជក្រឹត្យ [illegible] ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៥ ស្តីពីការ [illegible] ក្រសួងពាណិជ្ជកម្ម និងអាជីវកម្ម [illegible]

-យោងតាមបញ្ញត្តិប្រេងកាតកម្ពុជា ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩១

-តាមសំណើរបស់ឯកឧត្តម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

សម្រេច

មាត្រា ១ : កែសម្រួលមាត្រា ២ មាត្រា ៣, មាត្រា ៤ និងមាត្រា ៥ ក្នុងជំពូក ១ នៃបទបញ្ញត្តិប្រេងកាតកម្ពុជា លេខ ០១ បបញ្ញ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩១ ទៅតាមខ្លឹមសារដូចតទៅ :

មាត្រា ២: បន្ថែមពាក្យ « ដោយអនុលោមទៅតាមមាត្រាបន្ថែម ៥ក » នៅដើមកថាខណ្ឌនៃមាត្រានេះ និងកែថា « ៣០ថ្ងៃ » ត្រូវកែត្រូវជាថ្ងៃដែលកំណត់ « ៦០ថ្ងៃ » ។

មាត្រា ៣ : បន្ថែមពាក្យ « ដូចមានចែងនៅក្នុងមាត្រា២ » នៅចុងបញ្ចប់ទី១ នៃមាត្រានេះក្រោយពាក្យ « សំណើការផ្តល់ [illegible] » ។

មាត្រា ៤ : បន្ថែមពាក្យ « ដោយអនុលោមតាមការផ្តល់សិទ្ធិអាជ្ញាប័ណ្ណដូចបានចែងនៅក្នុងមាត្រា ២ » នៅដើមកថាខណ្ឌនៃមាត្រានេះ ។

មាត្រា ៥ : បន្ថែមពាក្យ « ដោយអនុលោមតាមការផ្តល់សិទ្ធិអាជ្ញាប័ណ្ណដូចបានចែងក្នុងមាត្រា ២ » នៅដើមកថាខណ្ឌនៃមាត្រានេះ ។

បន្ទាប់ពីកថាខណ្ឌ [illegible] ២ នៃប្រការ ៥ [illegible] បន្ថែម មាត្រាបន្ថែម ៥ក ដែលមានខ្លឹមសារ ដូចតទៅ :

មាត្រាបន្ថែម (៥ក) គោលការណ៍ជានីតិវិធី :

ក្នុងករណី ដែលគណៈទេសៈតំរូវអោយមាន [illegible] យកគួរ [illegible] ទៀតទៅទៀត [illegible] ដែលមានចែងក្នុងមាត្រា ២ [illegible]

៥ ក្នុងជំពូក២ នៃបទ បញ្ញត្តិប្រេងកាតកម្ពុជា ដែលនៅជាធរមាននេះនីតិវិធីខាងក្រោមអាចត្រូវបានលើកយក មកអនុវត្ត ដូចតទៅ :

ក / ក្រសួងឧស្សាហកម្ម រៀបចំបែបបទជូនដំណឹងស្តីពីការដេញថ្លៃទៅបណ្តាក្រុមហ៊ុន ។

ខ / ក្រសួងឧស្សាហកម្ម មានភារកិច្ច និងទទួលពាក្យសុំដេញថ្លៃ និងអនុវត្តនូវបែបបទចាំបាច់មួយចំនួន ដើម្បីបំពេញសំណុំរឿងចុះបញ្ជីការ ។

គ / គណៈកម្មការបច្ចេកទេសអន្តរក្រសួងសំរាប់កិច្ចរុករក និងអាជីវកម្មប្រេងកាតត្រូវទទួលបន្ទុករៀបចំបង្កើតឡើងនូវលក្ខណៈវិនិច្ឆ័យសមស្រប សំរាប់ការវាយតំលៃពិនិត្យពិចារណាលើពាក្យសុំដេញថ្លៃ និងការជ្រើសរើសក្រុមហ៊ុន ។

ឃ/ គណៈកម្មការបច្ចេកទេសអន្តរក្រសួង សំរាប់កិច្ចរុករក និងអាជីវកម្មប្រេងកាតមានភារកិច្ចរៀបចំបែបបទ ដើម្បីសុំការសំរេចរបស់រាជរដ្ឋាភិបាល ចំពោះក្រុមហ៊ុនដែលនឹងចុះកិច្ចព្រមព្រៀងជាមួយ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហប្រធាននៃគណៈកម្មការបច្ចេកទេសអន្តរក្រសួងសំរាប់កិច្ចការរុករក និង អាជីវកម្មប្រេងកាត រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ព្រមទាំងក្រសួង ស្ថាប័ន ខេត្ត-ក្រុងដែល មានការពាក់ព័ន្ធ ត្រូវទទួលការអនុវត្តន៍តាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថ លេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្ថលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៧៤ សសរ

ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន

* * *

រាជរដ្ឋាភិបាលកម្ពុជា

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែល ប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– ផ្អែកតាមការចាំបាច់

សំរេច

ប្រការ ១ : ប្រគល់ភារកិច្ចជូនឯកឧត្តម **យូ ហុកគ្រី** សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជារដ្ឋមន្ត្រីស្តីទីក្រសួងសាធារណការនិងដឹកជញ្ជូនចាប់ពីថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៥ រហូតដល់ឯកឧត្តម **អ៊ឹង គៀត** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនត្រឡប់មកពីបំពេញបេសកកម្មនៅទីក្រុងប៉ារីស ប្រទេសបារាំង និងនៅប្រទេសសឹង្ហបុរីវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តម **យូ ហុកគ្រី** ត្រូវ ទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានិង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៧៥ សសរ

ស្តីពីការផ្ទេរសិទ្ធិ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– យោងតាមការចាំបាច់

សំរេច

ប្រការ ១ : ក្នុងឱកាសដែលសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ និង សម្តេចនាយករដ្ឋមន្ត្រីទី ២ ត្រូវយាងទៅបំពេញព្រះរាជបេសកកម្ម និង អញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥ ការងារប្រចាំថ្ងៃរបស់រាជរដ្ឋាភិបាល ត្រូវបាន ផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រីសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ជូនឯកឧត្តម **យូ ហុកគ្រី** សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាសហនាយករដ្ឋមន្ត្រីស្តីទី រហូតដល់ពេលសម្តេចនាយករដ្ឋមន្ត្រីទាំងពីរយាង និងអញ្ជើញត្រឡប់មកមាតុភូមិវិញ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង សាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តការកិច្ចនេះរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្ថលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៧៥ សសរ

ស្តីពីការផ្ទេរភារកិច្ចដឹកនាំការងារ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤/៨៣ចុះថ្ងៃទី២៤ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញសេចក្តីសំរេចលេខ ៥០ សសរ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យ និងដេញថ្លៃឈើដែលនៅសេសសល់ក្រោយឱសានវាទ
- តាមសំណើរបស់ប្រធានគណៈកម្មការត្រួតពិនិត្យ និង ដេញថ្លៃឈើនៅសេសសល់ក្រោយឱសានវាទ

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរភារកិច្ចជូនឯកឧត្តម **កែ គីមយ៉ាន** ជាប្រធានស្តីទី នៃគណៈកម្មការត្រួតពិនិត្យ និង ដេញថ្លៃឈើដែលនៅសេសសល់ក្រោយឱសានវាទ ដឹកនាំការងារជំនួសឯកឧត្តម **តាវ សេងហួរ** ជាប្រធានគណៈកម្មការដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ចាប់ពី ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥៥ រហូតដល់ថ្ងៃឯកឧត្តម **តាវ សេងហួរ** វិលត្រឡប់មកវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ឯកឧត្តម អស់លោកដែលមាន ឈ្មោះក្នុងប្រការ ១ និងប្រការ ៣ នៃសេចក្តីសំរេចលេខ ៥០ សសរ ចុះថ្ងៃទី

១៧ ខែ កក្កដា ឆ្នាំ ១៩៩៥ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានិងចុះហត្ថលេខាតទៅ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខានិងត្រា ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៧៦ សសរ

ស្តីពីការងាររៀបចំចូលរួមក្នុងកិច្ចប្រជុំលើកទី១នៃក្រុមពិគ្រោះយោបល់ (First Consultative Group Meeting)

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស./រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតំរូវការចាំបាច់

សំរេច

ប្រការ ១ : ប្រគល់សិទ្ធិជូនឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការទីតិសម្បទា និងអភិវឌ្ឍន៍ អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការដឹកនាំ និងសំរបសំរួលការងាររៀបរៀបចំ ដើម្បីចូលរួមក្នុងកិច្ចប្រជុំលើកទី១ នៃក្រុមពិគ្រោះយោបល់(First Consultative Group Meeting) ដែលនឹងប្រព្រឹត្តទៅក្នុងឆមាសទី ១ ឆ្នាំ ១៩៩៦ ។

ប្រការ ២ : ក្នុងក្របខ័ណ្ឌនៃការដឹកនាំ និង សំរបសំរួលការងារត្រៀមរៀបចំ ដើម្បីចូលរួមក្នុងកិច្ចប្រជុំនេះឯកឧត្តម **គាត ឈន់** ត្រូវសហការជាមួយក្រសួងផែនការ និង មានសិទ្ធិអញ្ជើញមន្ត្រីជាន់ ខ្ពស់របស់បណ្តាក្រសួង និងស្ថាប័ននានារបស់រាជរដ្ឋាភិបាល អោយចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួង និង មានសិទ្ធិចាត់ចែងធ្វើការពិគ្រោះយោបល់ជាមួយតំណាងប្រទេស និងអង្គការអន្តរជាតិ អ្នកផ្តល់ជំនួយទ្វេភាគី ពហុភាគីនានា ដើម្បីសំរបសំរួលការងារ និងដើម្បីរៀបចំពង្រាងឯកសារចាំបាច់នានា ។

ប្រការ ៣ : ឯកឧត្តម **គាត ឈន់** ត្រូវរាយការណ៍ជាបន្តបន្ទាប់ថ្វាយសម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១ និងជូនសម្តេចនាយករដ្ឋមន្ត្រីទី២ អំពីលទ្ធផលនៃការងារដែលបានបំពេញ ហើយត្រូវរៀបចំ ឯកសារចាំបាច់ផ្សេងៗសំរាប់កិច្ចប្រជុំលើកទី១ នៃក្រុមពិគ្រោះយោបល់ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រី ពិនិត្យ និងផ្តល់យោបល់ណែនាំ មុននឹងយកទៅប្រើប្រាស់ជាផ្លូវការ ។

ប្រការ ៤ : ក្នុងការបំពេញកិច្ចការនេះ ឯកឧត្តម **គាត ឈន់** ត្រូវប្រើប្រាស់មធ្យោបាយនានារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គណៈកម្មាធិការទីតាំងសម្បទានិងអភិវឌ្ឍន៍កម្ពុជា (ក.អ.ក/គ.ជ.ន)និងមន្ត្រីក្រសួងផែនការ សំរាប់ជាជំនួយក្នុងការងារប្រចាំថ្ងៃ ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃបណ្តាក្រសួង និងរដ្ឋលេខាធិការដ្ឋានដែលមានការពាក់ ព័ន្ធ និងឯកឧត្តម **គាត ឈន់** ត្រូវអនុវត្តសេចក្តីសំរេចនេះចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

ប្រការ ៦ : សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និង ចុះ ហត្ថលេខា រហូតដល់កិច្ចប្រជុំលើកទី១ នៃក្រុមពិគ្រោះយោបល់បានប្រព្រឹត្តទៅចប់សព្វគ្រប់ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

៣—សេចក្តីជូនដំណឹង

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីថ្លែងហេតុលេខ ៥៦ សជណ.សរ

សេចក្តីព្រាងច្បាប់ ស្តីពីការការពារ

បេតិកភ័ណ្ឌវប្បធម៌

* * *

អនុលោមតាមមាត្រា ៦៩–៧០ និង ៧១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាសេចក្តីព្រាងច្បាប់ស្តីពីការការពារបេតិកភ័ណ្ឌវប្បធម៌នេះមានកម្មវត្ថុ ការពារសម្បត្តិវប្បធម៌ទាំងអស់ប្រឆាំងទប់នឹងអំពើ បំផ្លិចបំផ្លាញការផ្ទេរកម្មសិទ្ធិដោយខុសច្បាប់ ការជីកស្រាវជ្រាវ ការនាំចេញ និងការនាំចូលដែលខុសច្បាប់ ។

កន្លងមក ដើម្បីការពារបេតិកភ័ណ្ឌវប្បធម៌ជាតិ មានក្រឹត្យ–ច្បាប់លេខ ២១ ក្រច ចុះថ្ងៃទី១៨ មីនា ឆ្នាំ ១៩៨៥ ស្តីអំពីការគ្រប់គ្រងបេតិកភ័ណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ រមណីដ្ឋាន និងវិមានធម្មជាតិហើយនិងច្បាប់ ស្តីពីការការពារបេតិកភ័ណ្ឌវប្បធម៌ជាតិ រៀបចំដោយអង្គការយូណេស្កូ និងអនុម័ត ដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា កាលពីថ្ងៃទី ១០ កុម្ភៈឆ្នាំ ១៩៩៣ ។ ក៏ប៉ុន្តែក្រឹត្យនិងច្បាប់នេះ ពុំឆ្លើយតបបានសមស្របសំរាប់យកទៅអនុវត្តមានប្រសិទ្ធភាពក្នុងកាលៈទេសៈសព្វថ្ងៃ ក៏ដូចជាទៅអនាគតយូរអង្វែងនោះឡើយ ។

នៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ព្រះករុណាជាម្ចាស់ជីវិតតំកល់លើត្បូងទ្រង់បានឡាយព្រះហស្តលេខា លើព្រះរាជក្រឹត្យបង្កើតស្ថាប័នពីរគឺ ÷

–ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ (គជវជ) និង

–អាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ (អប្សរា) ដែលត្រូវទទួលបន្ទុកការពារអភិរក្ស និង ការលើកតំលៃបេតិកភ័ណ្ឌវប្បធម៌ជាតិ នៅក្នុងតំបន់អង្គរ និងនៅទីដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ។

សេចក្តីព្រាងច្បាប់នេះនឹងបំពេញអោយគ្រប់ខ័ណ្ឌច្បាប់មួយ ដើម្បីគ្រប់គ្រងវិស័យអភិរក្ស និង ការពារបេតិកភ័ណ្ឌវប្បធម៌ជាតិ ។

ដើម្បីសំរេចទិសដៅ ដូចមានចែងក្នុងកម្មវត្ថុ ដូចពោលខាងលើ សេចក្ដីព្រាង ច្បាប់នេ បានលើកឡើងនូវគោលការណ៍សំខាន់ៗ មានជាអាទិ៍ :

–ការកំណត់តំបន់ត្រូវការពារ ដើម្បីធានាដល់ការការពារអោយមានប្រសិទ្ធភាពនូ រមណីយដ្ឋានប្រវត្តិសាស្ត្រទាំងឡាយ ដែលនៅក្នុងបរិវេណនៃរមណីដ្ឋានទាំងនោះ សម្បត្តិវប្បធ ទាំងឡាយត្រូវចាត់ទុកជាសម្បត្តិសាធារណៈជាស្វ័យប្រវត្តិ (ជំពូក២, ផ្នែក ២)

–ការធ្វើបញ្ជីសារពើភ័ណ្ឌ និង ការចាត់ថ្នាក់ជាសម្បត្តិវប្បធម៌សាធារណៈ ឬ ឯកជ ដើម្បី ត្រួតពិនិត្យនូវរាល់ការផ្ទេរកម្មសិទ្ធិនៃសម្បត្តិវប្បធម៌ និងធានាការពារសម្បត្តិទាំងនោ ប្រឆាំងនឹងការលួចការនាំចេញខុសច្បាប់ ។ ក្នុងករណីខ្លះ សេចក្ដីព្រាងច្បាប់នេះគ្រោងអោយ រដ្ឋមានសិទ្ធិបុព្វក្រ័យ និងដក ហូតកម្មសិទ្ធិទៀតផង(ជំពូក ២ ផ្នែកទី៣ ទី៤និងទី៥) ។

–ការកំណត់បែបបទ ស្ដីពីពាណិជ្ជកម្មសម្បត្តិវប្បធម៌ ការរកឃើញដោយចៃដន្ ការជីករក វត្ថុបូរាណ ការនាំចេញ និង ការនាំចូលសម្បត្តិវប្បធម៌ ដើម្បីប្រយុទ្ធប្រឆាំងនឹងកា រត់ពន្ធសម្បត្តិ វប្បធម៌ដែលអាចនាំអោយក្សត់ខ្សោយដល់បេតិកភ័ណ្ឌជាតិខ្មែរ (ជំពូក២ ផ្នែក ៦, ៧, ៨, ៩,១០) ។

+ ផ្នែកទី៤ ស្ដីពីកិច្ចការពារតាមផ្លូវច្បាប់ និង ទោសបញ្ញត្តិ កំណត់នីតិវិធី ចំពោះករណី ដែល ពាក់ព័ន្ធនិងបទល្មើសនឹងបទព្រហ្មទណ្ឌ ដែលទាក់ទងនឹងកិច្ចការពារបេតិកភ័ណ្ឌជាតិ នេះ ។

ពេលដែលច្បាប់នេះ ចូលជាធរមានរាជរដ្ឋាភិបាលជឿថា រាជការកម្ពុជា

–នឹងពាក់ចែងវិធានការជាបន្ទាន់និងជាចាំបាច់ ដើម្បីបង្ក្រាបការរត់ពន្ធសម្បត្តិ វប្បធម៌ជាតិ

–អាចចុះបញ្ជីរមណីយដ្ឋានអង្គរទៅក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោក

–អាចអនុវត្តរាល់កាតព្វកិច្ច ដែលមានចែងក្នុងអនុសញ្ញាយូណេស្កូ ឆ្នាំ ១៩៧០ ហើយ ទទួលបានវិញនូវយន្តការការពារ ដែលមានគ្រោងក្នុងអនុសញ្ញានេះ ។

–អាចធានាបានជាលំដាប់នូវកិច្ចការពារតាមច្បាប់ និងប្រកបដោយប្រសិទ្ធភាពនូវ បេតិកភ័ណ្ឌ ជាតិខ្មែរ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន

* * *

II - ការងារបណ្ដាក្រសួង

១— ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៣៣៧ ប្រក.សហវ,ថ

ស្ដីពីអំពីការបែងចែកឥណទាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្ដេចព្រះនរោត្ដម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/ ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្ដីពីការកែតំរូវ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៥

- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៧៤ អនក្រ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរាជរដ្ឋាភិបាលលេខ ៧៧ អនក្របក ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីចំណាយឥតគ្រោងទុក
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ៣៣៨ចុះថ្ងៃទី១៦ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងតាមជំពូក ប្រការ កថាខណ្ឌ និងវាក្យខណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុងច្បាប់ ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជនលេខ ១១៣៣ សកអ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានផ្តល់ឥណទានបន្ថែមក្នុងសៀវភៅថវិការបស់ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនចំនួន មួយរយប្រាំបីលានរៀល (១០៨.០០០.០០០រៀល) ដោយបែងចែកនៅក្នុងជំពូក ១១ តាមប្រការ កថាខណ្ឌ វាក្យខណ្ឌ ដូចតទៅ ÷

ជំពូក	ប្រការ	កថាខណ្ឌ	វាក្យខណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ឥណទានកែតម្រូវ	ឥណទានផ្តល់បន្ថែម	ស្ថានភាពឥណទានថ្មី
11	01	12	03	សិក្ខាសាលាឬកិច្ចប្រជុំ	4.500.000	19.039.000	23.539.000
11	02	01	01	សោហ៊ុយដឹកជញ្ជូន	2.200.000	34.647.000	36.847.000
11	02	01	03	សោហ៊ុយស្នាក់នៅ	12.800.000	54.314.000	67.114.000

ប្រការ ២ : ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឆាយ ថន

* * *

២— ទីស្តីការរដ្ឋមន្ត្រីក្រសួងព័ត៌មាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២៦០/៩៥ ពម.ប្រក

ស្តីពីការអនុញ្ញាតផ្ទេរសិទ្ធិចាងហ្វាងការផ្សាយសារព័ត៌មាន

« សាធារណរដ្ឋ » ពីលោកគោគ សុផល មកលោក លឹម រតនា វិញ

* * *

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិមាត្រាទី១៥៣

– បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះនរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញច្បាប់សារព័ត៌មាន ត្រូវបានរដ្ឋសភា នៃរដ្ឋកម្ពុជាអនុម័តតាមសម័យប្រជុំវិសាមញ្ញថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី១

– បានឃើញប្រកាសអនុញ្ញាតលេខ ១៤៨–៩៥ ពម.ប្រក ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៥ ។

– បានឃើញលិខិតចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៥ របស់លោក **គោគ សុផល** ស្នើ សុំផ្ទេរសិទ្ធិចាងហ្វាងការផ្សាយសារព័ត៌មាន « សាធារណរដ្ឋ » ជូនមកលោក **លឹម រតនា** វិញ ។

សំរេច

ប្រការ ១ : យល់ព្រមតាមសំណើសុំផ្ទេរសិទ្ធិពីលោក **តោគ សុផល** ជាងហ្វាងការផ្សាយសារពតិមាន « សាធារណរដ្ឋ » មកលោក **លឹម រតនា** វិញ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និងសកម្មភាពផ្សព្វផ្សាយត្រូវស្របតាម ទំនៀមទំលាប់ ប្រពៃណីល្អ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមគោលការណ៍ ក្រមសីលធម៌ អ្នកកាសែត និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈ របស់ខ្លួន និងផ្ញើប្រគល់កាសែតចំនួន ១៥ ច្បាប់រៀងរាល់លេខចេញផ្សាយមក តំកល់ទុកជាឯកសារ នៅក្រសួងពតិមាន ។

ប្រការ ៤ : លោក **លឹម រតនា** ជាងហ្វាងការផ្សាយសារពតិមាន « សាធារណរដ្ឋ » និងនាយកដ្ឋានមណ្ឌលពតិមាន នៃក្រសួងពតិមាន ត្រូវអនុវត្ត នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២៦១/៩៥ ពម.ប្រក

អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅរូប

ភាគទី១ ផ្ទាំងរូបភាពបន្ថែមដោយមានលោក

KOJI TEZUKA **ជាប្រធាន** JSRC

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិ ហក្រមទី១១ ។

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** [illegible] នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣

ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០៨៩៥-០៧ ចុះថ្ងៃទី ០១ កញ្ញា ឆ្នាំ ១៩៩៥ ប្រកាសអោយប្រើច្បាប់ស្តីពីរបបសារពត៌មាននៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញលិខិតរបស់ក្រសួងពត៌មានលេខ ៥៦៨-៩៤ ចុះថ្ងៃទី ២៤ មិថុនា ឆ្នាំ១៩៩៤ អនុញ្ញាតអោយបន្តការបោះពុម្ពសៀវភៅរូបភាព និង ផ្ទាំងរូបភាព ស្រង់ចេញពីរឿងព្រេង ខ្មែរមួយចំនួន ។
- បានឃើញលិខិតលេខ ៥-៩៥ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៩៥ របស់ លោក KOJI TEZUKA ស្នើសុំបោះពុម្ពសៀវភៅរឿងខ្មែរបន្ថែមទៀត ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅរូបភាព និង ផ្ទាំងរូបភាពបន្ថែមដោយមាន លោក KOJI TEZUKA ប្រធាន JSRC នៃអង្គការជំនួយ ស្វ័តូស្ទ័ ជប៉ុនជាអ្នកទទួលខុសត្រូវលើការបោះពុម្ពផ្សាយ ។

ប្រការ ២ ខ្លឹមសារ អត្ថបទ និង សកម្មភាពផ្សព្វផ្សាយមិនត្រូវអោយប្រាសចាកពីរឿងដើម ឬ បញ្ចេញបញ្ចូលថែមខុសពីសាចរឿងពិត និង ត្រូវអោយសមស្របតាមទំនៀមទម្លាប់ប្រពៃណីល្អ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់សៀវភៅមួយមុខចំនួន ០៦ ក្បាល រៀងរាល់លេខចេញ ផ្សាយ មកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ លោក KOJI TEZUKA ជាចាងហ្វាងការផ្សាយ និង នាយកដ្ឋានមណ្ឌលពត៌មាននៃក្រសួងពត៌មាន ត្រូវអនុវត្តតាមប្រកាសនេះ ។

ប្រការ ៤ ប្រកាសនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២៦៤ ពត.ប្រក

ស្តីពីការលុបឈ្មោះមន្ត្រីរាជការ

ចេញពីក្របខ័ណ្ឌក្រសួង

-បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ០៦ ន.ស ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ អោយប្រើច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការ ស៊ីវិល ។

-បានឃើញអនុក្រឹត្យ ស្តីពីការកែលំអបៀវត្ស កម្មាភិបាល-បុគ្គលិក-កម្មករ រដ្ឋ លេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ១៩៩២ ។

-យោងតាមសំណើរបស់អគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជា លេខ ១១០ ប.ឈ ចុះថ្ងៃទី១៤ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

-យោងតាមសំណូមពររបស់សាមីខ្លួន

សម្រេច

ប្រការ ១ : លុបឈ្មោះ លោកស្រី **អ៊ុក សៅរី** ជាបុគ្គលិកដែលបានចូលបំរើការងារចាប់ពីថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៧៩ ចេញពីក្របខ័ណ្ឌ អគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជា នៃក្រសួងពត៌មានចាប ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៥ តទៅ ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួនត្រូវបានទទួលម្តងគត់ គឺស្មើនឹងប្រាក់បៀវត្សសរុបប្រចាំខែតុលា នឹង ខ្លួនធ្លាប់បំរើការងារដែលមានដូចខាងក្រោម ៖

-លោកស្រី **អ៊ុក សៅរី** : ៤៩.៣៨០៛,០០ គុណ ១០ : ៤៩៣.៨០០៛,០០

ប្រការ ៣ : អគ្គនាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ អគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជា និងសាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២៦៥/៩៥ ពម.ប្រក

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិមាត្រាទី១៣៨
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០៨៩៥-០៧ ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ប្រកាសអោយប្រើច្បាប់ ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញពាក្យសុំផ្ទេរចាងហ្វាងកាសែត « សង្គ្រោះខ្មែរ » ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៩៥ ។
- បានឃើញលិខិតស្នើសុំរបស់លោក ជេត សន សុំអនុញ្ញាតបោះពុម្ពផ្សាយសារពត៌មាន « សង្គ្រោះជាតិ » ចុះថ្ងៃទី ១៩ កញ្ញា ១៩៩៥ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយដំណើរការបោះពុម្ពផ្សាយកាសែត « សង្គ្រោះជាតិ » ដែលមានលោក **ជេត សន** ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និងសកម្មភាពផ្សព្វផ្សាយត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណី និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន និងស្នើប្រគល់កាសែតចំនួន ០៦ ច្បាប់ មកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : លោកចាងហ្វាងការផ្សាយសារពត៌មាន «សង្គ្រោះជាតិ » និងនាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២៦៦/៩៥ ពម.ប្រក

អនុញ្ញាតអោយកាសែត CAMBODGE SOIR **ប្តូរឈ្មោះនិពន្ធនាយកពីលោក** PHILIPPE LATOUR **ជូនមកលោក** PIERRE GILLETTE **វិញ**

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិមាត្រា ទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០៨៩៥–០៧ ចុះថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ១៩៩៥ ប្រកាសអោយប្រើច្បាប់ ស្តីពីរបបសារព័ត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញប្រកាសក្រសួងព័ត៌មានលេខ ១០៤–៩៥ ពម.ប្រក ចុះថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ១៩៩៥ ស្តីពីការអនុញ្ញាតអោយកាសែត CAMBODGE SOIR ដំណើរការបោះពុម្ពផ្សាយ ។
- បានឃើញលិខិតរបស់លោក ម៉ាក់ វិទរ៍ អគ្គនិពន្ធនាយកកាសែត CAMBODGE SOIR ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីការប្តូរនិពន្ធនាយកការផ្សាយរបស់កាសែត ដដែលនេះ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយកាសែត CAMBODGE SOIR ប្តូរឈ្មោះនិពន្ធនាយកពីលោក PHILIPPE LATOUR ជូនមកលោក PIERRE GILLETTE វិញ ។

ប្រការ ២ : អត្ថបទ និងសកម្មភាពផ្សព្វផ្សាយត្រូវអនុវត្តតាមខ្លឹមសារ នៃប្រកាសក្រសួងពត៌មាន លេខ ១០៤-៩៥ ពម.ប្រក ចុះថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ១៩៩៥ និងស្នើប្រគល់កាសែតចំនួន ៦ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : លោក PIERRE GILLETTE និពន្ធនាយកការផ្សាយកាសែត CAMBODGE SOIR និងនាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២៦៧/៩៥ ពម.ប្រក

ស្តីពីការយល់ព្រម និង ទទួលស្គាល់មន្ត្រីរាជការ

* * *

- បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងសំណើលេខ ៣៤៨.៩៥ និងលេខ ៣២០.៩៥ ព.ម ចុះថ្ងៃទី ០៩ ខែ សីហា និង ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់ក្រសួងពត៌មាន ,
- យោងលិខិតលេខ ១១៤ និង ១១៧ ប.ល៩៥ ចុះថ្ងៃទី ២៧ និង២៩ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់អគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជា ,
- ពិនិត្យលើសំណូមពរ នៃភារកិច្ចចាំបាច់

សំរេច

ប្រការ ១ : យល់ព្រម និង ទទួលស្គាល់មន្ត្រីរាជការ ចំនួន ៤ នាក់ នៅអគ្គនាយកដ្ឋាន វិទ្យុជាតិ កម្ពុជា អោយមកបំរើការងារនៅទីស្តីការរដ្ឋមន្ត្រី ដូចមាននាយនាមខាងក្រោម :

១- លោក **សែត គីមថា** បំរើការងារនៅនាយកដ្ឋាន បុគ្គលិក និង រដ្ឋបាល

២- លោក **គីម សុវណ្ណ** -

៣- លោក **ហ៊ីង ឆួត** -

៤- លោក **រីក ថន** ជំនួយការ ឯកឧត្តម អនុរដ្ឋលេខាធិការ

ប្រការ ២ : ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួនក្នុងប្រការ ១ ត្រូវបានទទួលនៅទីស្តីការចាប់ពីពេលដែលអគ្គនាយកដ្ឋាន វិទ្យុជាតិ ផ្ទេរមកអោយទីស្តីការរដ្ឋមន្ត្រី ។

ប្រការ ៣ : អគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជា, អគ្គនាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ និងសាមីខ្លួន មានភារៈអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

៣—ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ០៤៦ សសរ.ស.ក

ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីពិនិត្យចាយតំលៃលើសម្បត្តិអចលនៈ គ្មានលទ្ធភាពជួសជុល របស់រាជាយស្ម័យយានកម្ពុជា

ក្រោមឱវាទក្រសួងសាធារណការ និង ដឹកជញ្ជូន

* * *

ឧបនាយករដ្ឋមន្ត្រី–រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១–១១–៩៣

–បានឃើញសំណើរបស់រាជាយស្វ័យយានកម្ពុជាលេខ ១១៨ រអយក.ស ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ចាត់តាំងគណៈកម្មការអន្តរក្រសួងមួយ ដើម្បីពិនិត្យនិងវាយតំលៃលើសម្បត្តិអចល័តគ្មានលទ្ធភាពជួសជុលរបស់រាជាយស្វ័យយានកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ÷

១–លោក	**ខិន គឹមស្រេង**	អនុរដ្ឋលេខាធិការ	ប្រធាន
២–លោក	**ឡោង គឹមស៊្រាង**	នាយករាជាយស្វ័យយានកម្ពុជា	សមាជិក
៣–លោក		មន្ត្រីតំណាង ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៤–លោក		មន្ត្រីតំណាង ក្រសួងការពារជាតិ	សមាជិក
៥–លោក		មន្ត្រីតំណាង ក្រសួងមហាផ្ទៃ	សមាជិក
៦–លោក		មន្ត្រីតំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៧–លោក		មន្ត្រីតំណាង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
៨–លោក	**សែម សម**	មន្ត្រីការិយាល័យគណនេយ្យ	សមាជិក
៩–លោក	**ស្វាយ គូ**	ប្រធានគណនេយ្យ នាយកដ្ឋានរាជាយស្វ័យយានកម្ពុជា	លេខាធិការ

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចចុះពិនិត្យជាក់ស្តែង និងវាយតំលៃលើសម្បត្តិអចល័តគ្មានលទ្ធភាពជួសជុល របស់រាជាយស្វ័យយានកម្ពុជា និង ធ្វើរបាយការណ៍ជូនថ្នាក់លើសំរេច ។

ប្រការ ៣ : លោកអគ្គនាយក–នាយកខុទ្ទកាល័យ នាយករាជាយស្ម័យយានកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារ នៃសេចក្តីសំរេចនេះចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
ហត្ថលេខា និង ត្រា
អ៊ឹង គៀត

* * *

ភ្នំពេញ, ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥

៥—ទីស្តីការរដ្ឋមន្ត្រី ក្រសួងផែនការ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៦ ប្រ.ផក

ស្តីពីលទ្ធផលប្រឡងបញ្ចប់ការសិក្សា

ថ្នាក់ជំនាញស្ថិតិសេដ្ឋកិច្ចជំនាន់ទី VI

* * *

រដ្ឋមន្ត្រីក្រសួងផែនការ

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

–យោងសេចក្តីជូនដំណឹងលេខ ៥៣០ សណផក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩២ ស្តីពីការប្រឡងជ្រើសរើសសិស្សជំនាន់ទី VI អោយចូលរៀនសាលាមធ្យមសិក្សាផែនការ ។

–យោងប្រកាសលេខ ០១ ប្រ.ផក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៥ របស់ក្រសួងផែនការស្តីពីការចាត់តាំងគណៈកម្មការប្រឡងបញ្ចប់ការសិក្សាផ្នែកស្ថិតិសេដ្ឋកិច្ច ជំនាន់ ទី VI ។

–យោងតាមស្មារតីនៃសម័យប្រជុំអនុម័តលទ្ធផលនៃការប្រឡងបញ្ចប់ការសិក្សានាថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : និស្សិតផ្នែកជំនាញស្ថិតិសេដ្ឋកិច្ចជំនាន់ទី VI ទាំងពីរភេទដែលមានរាយនាមក្នុងតារាងឧបសម្ព័ន្ធទី I នេះត្រូវបានទទួលស្គាល់ថា : បានប្រឡងបញ្ចប់ការសិក្សារបស់ខ្លួនជាប់ជាស្ថាពរ ។

ប្រការ ២ : និស្សិតផ្នែកជំនាញស្ថិតិសេដ្ឋកិច្ចជំនាន់ទី VI ទាំងពីរភេទដែលមានរាយនាមក្នុងតារាងឧបសម្ព័ន្ធទី II ត្រូវបានទទួលស្គាល់ថា : បានប្រឡងបញ្ចប់ការសិក្សារបស់ខ្លួនលើកទី ២ ជាប់ជាស្ថាពរ ។

ប្រការ ៣ : និស្សិតទាំងអស់ដូចមានរាយនាមក្នុងតារាងឧបសម្ព័ន្ធទី I និង តារាងឧបសម្ព័ន្ធទី II ត្រូវបានទទួលស្គាល់ថា : ជាអ្នកឯកទេសថ្នាក់មធ្យមស្ថិតិ ។

ប្រការ ៤ : និស្សិតមានឈ្មោះក្នុងប្រការ១ ប្រការ ២ និងអង្គភាពពាក់ព័ន្ធត្រូវអនុវត្តតាមសេចក្តីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
ជា ចាន់តូ

* * *

៥— ទីស្តីការក្រសួងធម្មការ និង សាសនា

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២២៤/៩៥ កធស.ប្រក

ស្តីពីការយល់ព្រមទទួលស្គាល់មន្ត្រីរាជការ

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១-១១-៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ កុម្ភៈ ១៩៩២
- បានអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា
- បានឃើញប្រកាសលេខ ១៥៥ ប្រកវវស ចុះថ្ងៃទី ០៩ កញ្ញា ១៩៩៥ របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

សម្រេច

ប្រការ ១ : ទទួលស្គាល់មន្ត្រីរាជការ ០២ នាក់ ដែលផ្ទេរពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង ក្របខ័ណ្ឌ ០២ កន្លែង ក្នុងក្រសួងធម្មការ និង សាសនា ។

១- លោក **ខៀង សារិទ្ធ**

២- លោក **សៅ មេង**

ប្រការ ២ : ផ្លាស់លោកទាំងពីរដែលមានឈ្មោះក្នុងប្រការ ១ អោយទៅបំរើការងារនៅការិយាល័យធម្មការ និង សាសនា ស្រុកអង្គរជ័យ ។

ប្រការ ៣ : បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ អាស្រ័យដោយមន្ទីរធម្មការ និង សាសនា ជាអ្នកទទួលរៀបចំ និង ចាត់ចែង ។

ប្រការ ៤ : មន្ទីរធម្មការ និង សាសនាខេត្ត , មន្ទីរផែនការ, មន្ទីរហិរញ្ញវត្ថុខេត្តកំពត , ការិយាល័យស្រុកមានជ័យ និងសាមីខ្លួន ត្រូវអនុវត្តរៀងៗ ខ្លួនតាមប្រកាសនេះ ។

ប្រការ ៥ : សេចក្តីប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

ហត្ថលេខា និង ត្រា

ហៀង វណ្ណារិទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២២៥/៩៥ កធស.ប្រក

ស្តីពីការទទួលស្គាល់ជាផ្លូវការរចនាសម្ព័ន្ធ និង

ក្របខ័ណ្ឌមន្ទីរធម្មការនិងសាសនា ខេត្តតាកែវ

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជាចុះ ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

–បានឃើញច្បាប់ ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២

–បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ដែលរៀបចំ និង ប្រព្រឹត្តិទៅនៃក្រសួងធម្មការ និងសាសនា ។

–បានឃើញលិខិតលេខ ១៦២–៩៥ មធស.តក ចុះថ្ងៃទី ១៥ ខែ ៩ ឆ្នាំ១៩៩៥ របស់មន្ទីរធម្មការ និង សាសនា ខេត្ត តាកែវ ។

សំរេច

ប្រការ ១ : ទទួលស្គាល់រចនាសម្ព័ន្ធ និងក្របខ័ណ្ឌ និងបញ្ជីរាយនាមមន្ត្រីរាជការក្នុងមន្ទីរធម្មការ និង សាសនា ខេត្តតាកែវដូចខាងក្រោម :

១– លោក ពុធ ខូវ	ជាប្រធានមន្ទីរ
២– លោក កែវ ហ៊ុច	អនុប្រធានមន្ទីរធម្មការ និងសាសនាខេត្ត
៣– លោក សិល សុខសា៊ន	ប្រធានការិយាល័យរដ្ឋបាល
៤– លោក ង៉ែត ខិត	អនុប្រធានការិយាល័យរដ្ឋបាល
៥– កញ្ញា ម៉ឹង មុំ	បុគ្គលិក
៦–អ្នកស្រី ឥន្ទ ណារី	បេឡាធិការ
៧–អ្នកស្រី ជា សំអឿន	អង្គុលីលេខ
៨–លោក យង់ យ៉េម	បើកបរ

៩-អ្នកស្រី សុខ សុខុម ប្រធានការិយាល័យធម្មការ
១០-លោក ម៉ៅ ភន អនុប្រធានការិយាល័យធម្មការ
១១-លោក រឿង សុក មន្ត្រីជំនួយការការិយាល័យធម្មការ
១២-លោក អួច ពិន ប្រធានការិយាល័យពុទ្ធិកសិក្សា
១៣-លោក ស៊ុម កួយ អនុប្រធានការិយាល័យពុទ្ធិកសិក្សា
១៤-លោក សូ ពេញ អនុប្រធានការិយាល័យពុទ្ធិកសិក្សា
១៥-លោក ជា វណ្ណា ប្រធានការិយាល័យធម្មការស្រុកព្រែកឬស្ស
១៦-លោក ម៉ុក តុង អនុប្រធានការិយាល័យធម្មការស្រុកព្រែកឬស្ស
១៧-លោក សួន ភន ប្រធានការិយាល័យធម្មការនិងសាសនាស្រុកកោះអណ្តែត
១៨-លោក ព្រំ ព្រាប អនុប្រធានការិយាល័យស្រុកកោះអណ្តែត
១៩-លោក ឈឹម ផែន ប្រធានការិយាល័យធម្មការស្រុកអង្គរបុរី
២០-លោក ហិយ សំអឿន អនុប្រធានការិយាល័យស្រុកអង្គរបុរី
២១-លោក ឌី សាមឿន ប្រធានការិយាល័យធម្មការស្រុកសំរោង
២២-លោក សាំង សារិន អនុប្រធានការិយាល័យធម្មការស្រុកសំរោង
២៣-លោក កែវ ណម ប្រធានការិយាល័យធម្មការស្រុកទ្រាំង
២៤-លោក ចាន់ សន អនុប្រធានការិយាល័យធម្មការស្រុកទ្រាំង
២៥-លោក ឌន រី ប្រធានការិយាល័យធម្មការស្រុកត្រាំកក់
២៦-លោក ទេព ប៊ុន អនុប្រធានការិយាល័យធម្មការស្រុកត្រាំកក់
២៧-លោក ស៊ឹម សុន ប្រធានការិយាល័យធម្មការស្រុកបូរីជលសារ
២៨-លោក ញ៉ូ ឆាន់ អនុប្រធានការិយាល័យធម្មការស្រុកបូរីជលសារ
២៩-លោក ង៉ែត ឆន ប្រធានការិយាល័យធម្មការស្រុកដូនកែវ
៣០-លោក សេក បេន អនុប្រធានការិយាល័យធម្មការស្រុកដូនកែវ
៣១-លោក គង់ ម៉ាក ប្រធានការិយាល័យធម្មការស្រុកគិរីវង់
៣២-លោក ទឹម ដេត អនុប្រធានការិយាល័យធម្មការស្រុកគិរីវង់
៣៣-លោក សុខ សារ៉ាន់ ប្រធានការិយាល័យធម្មការស្រុកបាទី
៣៤-លោក អ៊ឹង ឡេង អនុប្រធានការិយាល័យធម្មការស្រុកបាទី

ប្រការ ២ : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញកិច្ច នាយកដ្ឋានធម្មការ អគ្គាធិការដ្ឋានពុទ្ធិកសិក្សា ពុទ្ធសាសនបណ្ឌិត្យ ដើម្បីទទួលស្គាល់ជាផ្លូវការ ។

ប្រការ ៣ : សេចក្ដីប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

ហៀង វណ្ណារឿ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៤

ប្រកាសលេខ ២២៦/៩៥ កធស.ប្រក

ស្ដីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

–បានឃើញច្បាប់ស្ដីពីការបង្កើតទីស្ដីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនាដែល ប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។

–បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ដែល រៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។

–បានឃើញលិខិតចុះថ្ងៃទី១៨ ខែ កញ្ញា ឆ្នាំ១៩៩៥របស់នាយកដ្ឋានរដ្ឋបាល ហិរញ្ញកិច្ច

–អនុលោមតាមការចាំបាច់ និង សមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

ប្រការ ១ :តែងតាំងមន្ត្រីរាជការក្នុងនាយកដ្ឋានរដ្ឋបាល ហិរញ្ញកិច្ចដូចមានរាយនាមខាងក្រោម

១–លោក **សុខ ហួរ** បុគ្គលិក ជាអនុប្រធានការិយាល័យទទួលផ្នែក បៀវត្សពលកម្ម

២–លោក **សោម សេឿន** បុគ្គលិក ជាអនុប្រធានការិយាល័យទទួលគ្រប់គ្រង ជីវប្រវត្តិមន្ត្រីរាជការខេត្ត–ក្រុង ។

៣–លោក **អ៊ុម ណារ៉ង់** បុគ្គលិក អនុប្រធានការិយាល័យទទួលការ[illegible] រៀប

៤-អ្នកស្រី **តាន់ សុខា** បុគ្គលិក ជាអនុប្រធានការិយាល័យទទួលការងារ ឯកសារ

៥-អ្នកស្រី **ហ៊ិន ចុមឡេង** បុគ្គលិក ជាអនុប្រធានការិយាល័យទទួលការងារ អង្គុលីលេខ

៦-លោក **ម៉ិន ម៉េងសែ** បុគ្គលិក ជាអនុប្រធានការិយាល័យសមោធាន «សរុប»

ប្រការ ២ : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល ហិរញ្ញកិច្ច ការិយាល័យបុគ្គលិក និងអស់លោក អ្នកស្រីដែលមានឈ្មោះក្នុងប្រការមួយ ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះរៀង ៗ ខ្លួន ។

ប្រការ ៣ : សេចក្តីប្រកាសនេះ មានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

ហៀង សណ្ណារ័ត្ន

* * *

៦-ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៦៧ អយក.ប្រក

ស្តីពីការបង្កើត អនុវិទ្យាល័យ សម្តេច ហ៊ុន សែន

ក្នុងឃុំរនាម ស្រុកក្រូចឆ្មារ ខេត្ត តាកែវ

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច**នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤ ។

-បានឃើញក្រឹត្យ ច្បាប់លេខ ៣០ក្រច ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ស្តីពីប្រព័ន្ធ អប់រំចំណេះទូទៅ ។

-បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចខម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការ បើកសាលាមធ្យមសិក្សាកំរិត ១ កំរិត ២ ។

-យោងសំណើរបស់គណៈកម្មការសាងសង់សាលា ដោយមានយោបល់ឯកភាពពីប្រធាន មន្ទីរអប់រំយុវជន និងកីឡា និងអភិបាលខេត្តតាកែវ ។

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកអនុវិទ្យាល័យមួយកន្លែងដែលមានឈ្មោះថា « អនុវិទ្យាល័យសម្តេច **ហ៊ុន សែន** » ចាប់ពីឆ្នាំសិក្សា ១៩៩៥ ៩៦ តទៅ នៅក្នុងឃុំរនាម ស្រុកទ្រាំង ខេត្តតាកែវ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រម ទាំងបុគ្គលិកផ្សេងៗមួយចំនួនតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយកនាយករងនៃអនុវិទ្យាល័យ ។

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៦៧៣ អយក.ប្រក

ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ គរ ក្នុងស្រុកព្រៃឈរ

ខេត្តកំពង់ចាមទៅជា «អនុវិទ្យាល័យសម្តេចហ៊ុន សែន»

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែល ប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ។
- បានឃើញក្រឹត្យ ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ស្តីពីការ ប្រព័ន្ធអប់រំចំណេះទូទៅ
- តាមសំណើរបស់ប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ចាម ស្តីពីការ សុំប្តូរ ឈ្មោះ អនុវិទ្យាល័យគរទៅជា « អនុវិទ្យាល័យ សម្តេច ហ៊ុន សែន » ដោយ មានការឯកភាព ពីអភិបាលខេត្ត កំពង់ចាម ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះអនុវិទ្យាល័យគរ បច្ចុប្បន្នទៅជា « អនុវិទ្យាល័យសម្តេច **ហ៊ុន សែន** » ចាប់ពីបវេសនកាលឆ្នាំសិក្សា ១៩៩៥–៩៦ តទៅនៅក្នុងស្រុកព្រៃឈរខេត្តកំពង់ចាម ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋាន បុគ្គលិក និងប្រធាន នាយកដ្ឋានផែនការ និងហិរញ្ញកិច្ចនៃក្រសួងអប់រំយុវជន និងកីឡា មានភារកិច្ច រៀងៗខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តូល ឡាះ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៦៧៤ អយក.ប្រក
ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យព្រែកដំបង នៅក្នុងស្រុកមុខកំពូល ខេត្តកណ្តាលទៅជា «អនុវិទ្យាល័យសម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ»

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញក្រឹត្យ ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ឆ្នាំ១៩៨៦ ស្តីពីប្រពន្ធ័អប់រំចំណេះទូទៅ ។
- យោងសេចក្តីសំរេចលេខ ៣១៩ អរ.សសរ ចុះថ្ងៃទី ៣០ វិច្ឆិកា ឆ្នាំ ១៩៩១ ស្តីពីការបើកអនុវិទ្យាល័យខេត្តកណ្តាល ។
- តាមសំណើរបស់គណៈកម្មការសាងសង់ និងទ្រទ្រង់សាលាអនុវិទ្យាល័យព្រែកដំបង ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំយុវជន និងកីឡា និងអភិបាលខេត្តកណ្តាល ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះអនុវិទ្យាល័យ ព្រែកដំបង ក្នុងស្រុកមុខកំពូលខេត្តកណ្តាលទៅជា « អនុវិទ្យាល័យសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** » ចាប់ពីបវេសនកាលឆ្នាំសិក្សា ១៩៩៥– ៩៦ តទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មធ្យមសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក និងប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តូល ឡោះ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៦៧៥ អយក.ប្រក

ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យរកាខ្នុរ ក្នុងឃុំរកាខ្នុរស្រុក

ក្រូចឆ្មារខេត្តកំពង់ចាមទៅជា «អនុវិទ្យាល័យសម្តេចហ៊ុន សែន »

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ** ស្តីពីព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែល ប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញក្រឹត្យ ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ឆ្នាំ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ។
- តាមសំណើរបស់ចៅអធិការវត្តហ្លួង សមាគមមាតាបិតាសិស្សអនុវិទ្យាល័យរកាខ្នុរនិងរដ្ឋ អំណាចមូលដ្ឋានក្នុងឃុំរកាខ្នុរ ស្តីពីការសុំប្តូរឈ្មោះអនុវិទ្យាល័យរកាខ្នុរទៅជា«អនុវិទ្យា ល័យសម្តេច ហ៊ុន សែន » ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះអនុវិទ្យាល័យ រកាខ្នុរ បច្ចុប្បន្ន ទៅជា «អនុវិទ្យាល័យសម្តេច **ហ៊ុន សែន** »ចាប់ពីបវេសនកាលឆ្នាំសិក្សា ១៩៩៥–៩៦ តទៅនៅក្នុងស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក និង ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ចនៃក្រសួងអប់រំយុវជន និងកីឡា មានភារកិច្ច រៀងៗខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
តុល ឡោះ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៦៧៦ អយក.ប្រក
ស្តីពីការបើកវិទ្យាល័យបានលុង នៅខេត្ត រតនគីរី

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

–បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤ ។

–បានឃើញក្រឹត្យ ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ឆ្នាំ១៩៨៦ ស្តីពីប្រព័ន្ធអប់រំ ចំណេះទូទៅ ។

–តាមសំណើរបស់មន្ទីរអប់រំយុវជន និងកីឡា ខេត្ត រតនគីរី ស្តីពីការសុំបើកវិទ្យាល័យបានលុង ដោយមានការឯកភាពពីអភិបាលខេត្ត រតនគីរី ។

–តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយបើកវិទ្យាល័យមួយកន្លែងជាផ្លូវការដែលមានឈ្មោះថា «**វិទ្យាល័យ ឆានលុង**» ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ តទៅ នៅក្នុងទីរួមខេត្ត រតនគីរី ។

ប្រការ ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រម ទាំងបុគ្គលិកផ្សេងៗទៀតមួយចំនួនតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក នាយករង នៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ការកិច្ចរបស់នាយក នាយករងនៃវិទ្យាល័យ ។

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមធ្យមសិក្សា ប្រធាននាយកដ្ឋាន បុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុលា ឡោះ

* * *

៧—ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៧០ ប្រក.វវស.ប,

ស្តីពីការលុបឈ្មោះមន្ត្រីរាជការមន្ទីរ វប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ឆ្នាំង

* * *

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន**

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមសំណើលុបឈ្មោះលេខ ២២១-៩៥ លខវវស.កផ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ឆ្នាំង ។

-យោងតាមចំណាររយល់ព្រមពីឯកឧត្តមរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : អ្នកស្រី **ម៉ក់ សំអាត** បុគ្គលិកការិយាល័យវប្បធម៌ និង វិចិត្រសិល្បៈស្រុករលាប្អៀរ នៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តកំពង់ឆ្នាំងត្រូវបានអនុញ្ញាតអោយលុបឈ្មោះចេញពីបញ្ជីក្របខ័ណ្ឌមន្ត្រីរាជការមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តកំពង់ឆ្នាំងចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៥ ដោយសុំលាឈប់ពីការងារ និងបានទទួលរបបឧបត្ថម្ភតាមគោលនយោបាយតាមការកំណត់របស់រាជរដ្ឋាភិបាលកម្ពុជា ។

ប្រការ ២ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តកំពង់ឆ្នាំង និង អ្នកស្រី **ម៉ក់ សំអាត** មានភារកិច្ចអនុវត្តប្រកាសនេះ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

វ៉ែន ឃើត

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៧១ ប្រក.វវស.ប,

ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការ

មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ រាជធានីភ្នំពេញ

* * *

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ**

ឡុំន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមលិខិតសុំផ្លាស់ប្តូរកន្លែងធ្វើការពីមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានីភ្នំពេញទៅបំរើការងារនៅនាយកដ្ឋានសិល្បៈនិងទស្សនីយភាព របស់អ្នកស្រី ពេជ្រ. គន្ធា ចុះ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : អ្នកស្រី ពេជ្រ គន្ធា បុគ្គលិកការិយាល័យសិល្បៈនៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញត្រូវបានអនុញ្ញាតអោយផ្លាស់ទៅបំរើការងារនៅនាយកដ្ឋានសិល្បៈ និង ទស្សនីយភាព។

ប្រការ ២ :មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈរាជធានីភ្នំពេញនឹងផ្ទេរប្រាក់បៀវត្សរបបឧបត្ថម្ភផ្សេង ៗ របស់សាមីខ្លួននិងក្របខ័ណ្ឌមួយកន្លែងជូននាយកដ្ឋាន សិល្បៈនិងទស្សនីយភាព ។

ប្រការ ៣ : នាយកដ្ឋានបុគ្គលិកនិងកិច្ចការសង្គម នាយកដ្ឋានផែនការគណៈនេយ្យនិងហិរញ្ញវត្ថុ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈរាជធានីភ្នំពេញនិងសាមីខ្លួនមាន ភារកិច្ចអនុវត្តប្រកាសនេះ ។

អនុរដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ម៉ែន យ៉េត

* * *

៩— រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ១០៧៩ សសរ.មស.ប្រក

ស្តីពីការបែងចែកសិស្ស និស្សិតចំនួន ៩៧ នាក់

ដែលទើបបញ្ចប់ការសិក្សា ពីក្រៅប្រទេស

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៤៩.៨៣ ចុះថ្ងៃទី ២៤ខែ តុលាឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។

-យោងលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ៣១៩ សជណ.ផក ចុះថ្ងៃទី ២៨-០២- ៩៥ ។

សំរេច

ប្រការ ១ :អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រចំនួន ០២នាក់ អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ៨៦ នាក់ អ្នកបច្ចេកទេសថ្នាក់ពាក់កណ្តាលឧត្តមចំនួន ០១ នាក់ និងអ្នកបច្ចេកទេសថ្នាក់មធ្យមចំនួន ០៨នាក់ ដែលបានបញ្ចប់ការសិក្សាពីក្រៅប្រទេសត្រូវបានបែងចែកអោយទៅបំរើការងារនៅតាមក្រសួង ស្ថាប័នមួយចំនួន ដូចមានក្នុងតារាងឧបសម្ព័ន្ធ នៃសេចក្តីសំរេចនេះ ។

ប្រការ ២ : ក្រសួងនិងស្ថាប័នដែលពាក់ពន្ធ័មានភារកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះដើម្បីរៀបចំការងារអោយត្រូវតាមមុខជំនាញ និង ផ្តល់បៀវត្សជូនសាមីជនចាប់ពីថ្ងៃដែលគេបានចូលបំរើការងារជាផ្លូវការ ។

ប្រការ ៣ : សេចក្តីសំរេចនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ប្រាក់ សុខ

* * *

តារាងឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ១០៧៩ សសរ.មសរ.ក្រុម
ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកសិស្ស–
និស្សិតចំនួន ៩៧ នាក់ ដែលទើបបញ្ចប់ការសិក្សាពីក្រៅប្រទេស

* * *

ល.រ	នាមត្រកូល និង នាមខ្លួន	ភេទ	ថ្ងៃខែឆ្នាំ កំណើត	អង្គភាព ដើម	មុខជំនាញ បច្ចេកទេស	របៀវត្ស -	ប្រភពបណ្តុះ បណ្តាល
	១– ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទចំនួន ៣៣ នាក់						
	ក– អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ៣១ នាក់						
១	ទុយ សេរីវឌ្ឍនា	ប	០២.០២.៧០	សិស្ស	កែច្នៃឈើ	៩០អ.១	០១
២	លី គន	ប	០៤.៨.៦៨	-	អាជីវកម្មព្រៃឈើ	-	-
៣	ហួរ ចំនួរសី	ប	២២.៧.៦៩	-	ធារាសាស្ត្រ	-	-
៤	គ្រួច សារិទ្ធ	ប	១២.០១.៦៩	-	អាជីវកម្មព្រៃឈើ	-	-
៥	ផេង សុវណ្ណវុធី	ប	១២.១០.៦៧	-	បសុព្យាបាល	-	៣
៦	ហែរ សារ៉ាន់	ប	០៧.៦.៦៧	-	–	-	-
៧	អ៊ូ សារី	ប	០៧.៦.៦៦	-	កែច្នៃផលិតផលសមុទ្រ	-	-
៨	ពុទ្រា សុលីដា	ប	២៨.៥.៦៧	-	សេដ្ឋកិច្ចជលផល	-	-
៩	ចាន់ សុខហេង	ប	០៥.៥.៦៩	-	–	-	-
១០	សេង រ៉ាន់ធីរ៉ា	ប	០៥.៥.៦៩	-	–	-	-
១១	ថោង វិបុលរិទ្ធ	ប	១៥.៧.៦៥		ចិញ្ចឹមមច្ឆាវប្បកម្ម	-	-
១២	មាស វិចិត្រ	ប	០៧.៦.៧០	-	អាជីវកម្មជលផល	-	-
១៣	ឈួន គិមឈា	ប	១១.០២.៧២	-	នាវាចរ	-	-
១៤	យល់ ចន្ទាណា	ប	២០.១២.៧៣	-	–	-	-
១៥	គីង សុផានី	ប	១៦.៣.៧២	-	–	-	-
១៦	អ៊ីវ សុខសាន្ត	ប	០៥.៧.៧២	-	អាជីវកម្មជលផលនាវាចរ	-	-
១៧	ហុក ប៊ុនថុន	ប	០១.១០.៦៩	-	–	-	-
១៨	សំ ណារិទ្ធ	ប	០៦.៥.៧៣	-	–	-	-
១៩	រស់ គន្ធី	ប	០១.៣.៦៩	-	–	-	-
២០	អ៊ុង រចនា	ប	០១.៦.៦៧	-	–	-	-
២១	ប៊ុល មីម៉ូសា	ប	១០.៩.៧០	-	–	-	-

២២	អែម សាមី	ប	២៥.០៨.៦៨	-	–	-	១
២៣	ជាម យូសុង	ប	០៥.៦.៦៩	-	កែច្នៃផលិតផលសមុទ្រ	-	-
២៤	ម៉ម សុមុនី	ប	១៧.១២.៦៩	-	អាជីវកម្មព្រៃឈើ	-	-
២៥	ខៀវ សុវណ្ណារា	ប	១៥.៣.៦១	ប្ត.កំពង់ឆ្នាំង	បសុព្យាបាល	ខI.១	-
២៦	ហ៊ុយ វុទ្ធី	ស	០៥.៣.៦៨	សិស្ស	សេ.កីនិងការគ្រប់គ្រងតំបន់កសិកម្ម		
					ឧស្សាហកម្ម	៩០ខI.១	-
២៧	អ៊ុក ឧឡារី	ស	១៧.៦.៦៦	-	បច្ចេកវិទ្យាវាយនភ័ណ្ឌស្បែក កៅស៊ូ ក្រែប	-	-
២៨	នូ ទី	ប	១២.០១.៦៩	-	ចិញ្ចឹម «មច្ឆាវប្បកម្ម»	-	-
២៩	អ៊ួច ឡុង	ប	១១.១១.៦៧	-	–	-	-
៣០	នួយ មុនី	ប	១២.៣.៦៦	-	កសិកម្មតំបន់ត្រូពិក «ផ្នែកខាងសត្វ»	-	-
៣១	សោម វិទ្ធី	ប	១០.០២.៦៨	-	គីមីវិទ្យាផ្នែកកែច្នៃជ័រកៅស៊ូធម្មជាតិ	-	-

ខ— អ្នកបច្ចេកទេសថ្នាក់មធ្យមចំនួន ០២ នាក់

៣២	អ៊ុង សេរីវុឌ្ឍ	ប	០៣.៩.៦៦	-	បសុព្យាបាល	៩០ខII.១-	១
៣៣	យ៉ែម ខេមប្រិយា	ស	០៣.១១.៧២	-	កសិកម្ម ដំណាំ និងចិញ្ចឹមសត្វ	-	៥

២— ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពលចំនួន ១០ នាក់

ក— ថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ ភាគ ១ ចំនួន ០១ នាក់

៣៤	កែ គី	ប	០១.០១.៥៩	-	ម៉ូទ័រចំហេះក្នុងថ្នាស្ទីកចាក់អង្រែលើ	ខI.៤	១

ខ— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០៧ នាក់

៣៥	អ៊ិន ចំនួសុផល	ប	១៥.៥.៦៨	-	គីមីនៃអង្គធាតុសរីរាង្គ	៩០ខI.១	១
៣៦	ម៉ុង សុគន្ធារ័ត្ន	ប	០៦.០១.៦៩	-	បច្ចេកទេសរោងពុម្ព	-	-
៣៧	ពុត សារឿន	ប	០២.០២.៦៩	-	–	-	-
៣៨	ហ៊ុម គីមសាន	ប	០៥.៨.៦៨	-	–	-	-

៣៩	អ៊ុក ធារី	ប	១៩.០១.៦៩	-	បច្ចេកទេសផលិតផលអេឡិចត្រូនិច	-	១
៤០	សួន រតនា	ប	២៥.១២.៦៩	-	ប.ទេសគ្រឿងយន្ត	-	៥

គ— អ្នកបច្ចេកទេសថ្នាក់មធ្យមចំនួន ០២ នាក់

៤១	អ៊ូ សំអុល	ប	០៥.១០.៦៧	-	ពិនិត្យគុណភាពប្រេងម៉ាស៊ីន		៥
៤២	អ៊ឹម សំអាត	ប	០៦.៦.៧២	-	បច្ចេកទេសសំណង់គ្រឿងយន្ត	៩០៣II.១	-
៤៣	ហ៊ួត មុនី	ប	១៧.៨.៧២	-	ម៉ាស៊ីនឧស្សាហកម្ម	-	៣

៣—ក្រសួងសាធារណការ និង ដឹកជញ្ជូនចំនួន ១៧ នាក់

ក— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ១៣ នាក់

៤៤	[illegible]	ប	២៩.៩.៧០	-	មេកានិចម៉ាស៊ីន	៩០៣I.១	៣
៤៥	[illegible]	ប	៣០.១២.៧០	-	សំណង់ស្ពានថ្នល់	-	-
៤៦	[illegible]	ប	១០.៧.[illegible]	-	ផលិតនិងថែទាំម៉ាស៊ីនបំលោះក្លុក	-	១
៤៧	ស៊ីវ [illegible]	ប	០២.៥.[illegible]		មេកានិក	-	៤
៤៨	តាំង [illegible]	ប	០៨.៩.៧០		ផលិតនិងពិកតាប្រើប្រាស់គ្រឿងយន្ត	-	១
៤៩	សួន វាន់ហុង	ប	១៣.១២.៦៨	-	ម៉ាស៊ីននិងដឹកជញ្ជូនដោយរថយន្ត	-	១
៥០	គិម ម៉ានីណា	ប	១៥.៣.៦៨	-	សំណង់និងជួសជុលផ្លូវដែក	-	-
៥១	ម៉េង លី	ប	១៨.៨.៦៩	-	–	-	-
៥២	វ៉ៀម លីអេង	ស	០៨.៨.៦៨	-	សេ.កិនិងទិសដៅនៃការដឹកជញ្ជូនដោយរថយន្ត	-	-
៥៣	យូ រ៉ា	ប	០៥.៤.៧៣	-	–	-	-
៥៤	ឃិត សុវណ្ណារិទ្ធ	ប	២០.៥.៧២	-	សំណង់ស៊ីវិលនិងឧស្សាហកម្ម	-	-
៥៥	បែន សុភាព	ប	០៥.៣.៦៦	-	បច្ចេកទេសកបាល	-	៣

៥៦	ឃឹម រី	ប	១២.៤.៦៨	-	មាស៊ីននិងជីកជញ្ជូនដោយរថយន្ត	៩០៧.១	។
៥៧	ចាង សាយ	ប	០៦.៦.៧០	-	ជួសជុលនិងថែទាំដោយរថយន្ត	៩០៧.១	-
៥៨	មុំ មុនីវង្ស	ប	០១.០១.៧០	-	ជួសជុលកប៉ាល់	-	-
៥៩	គី សារឿន	ប	១៥.៥.៦៦	-	គ្រឿង	៧.១	-
៦០	ឯក ចិន្តាពិចិត្រ	ប	១២.០២.៧០	-	អាជីវកម្មរថភ្លើង	៩០៧.១	-

៤— ក្រសួងអប់រំយុវជន និង កីឡាចំនួន ១៣ នាក់

ក— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ១៣ នាក់

៦១	ហុក សុទ្ធិ	ប	២៤.១០.៦៩	-	ភាសាបារាំងនិងរុស្ស៊ី	៩០៧.១	។
៦២	លី សុខបូរ៉ា	ប	០១.៨.៦៨	-	ភាសានិងអក្សរសិល្ប៍រុស្ស៊ីនិងភាសាអង់គ្លេស	-	-
៦៣	សារុម ម៉ារឌី	ស	១៥.៤.៦៦	-	—	៧.១	-
៦៤	រ៉េន វុទ្ធី	ប	១០.៥.៦៨	-	—	៩០៧.១	-
៦៥	ព្រោក ឿន	ប	០៧.១២.៦៣	-	ទស្សនវិជ្ជា	៧.១	-
៦៦	ម៉ៅ ពៅ	ប	០៧.១២.៧០	-	ទ្រឹស្តីសេដ្ឋកិច្ច	៩០៧.១	-
៦៧	ឃោក វីរៈ	ប	០៥.៧.៦៧	-	—	-	-
៦៨	ណុប សុខា	ប	០៧.៣.៦៨	-	បច្ចេកទេសភោគពុម្ព	-	-
៦៩	រ៉េន ចាន់ថន	ប	០៥.១០.៦៩	-	—	-	-
៧០	ហេង គន្ធី	ប	១៨.៣.៧១	-	—	-	-
៧១	សេង អម្រា	ស	៣០.៧.៧០	-	ភាសានិងអក្សរសិល្ប៍រុស្ស៊ី	-	-
៧២	ហ៊ីង រតនា	ប	០១.១០.៦៩	-	គណិតវិទ្យា រូបវិទ្យានិងកុំព្យូទ័រ	-	-
៧៣	អ៊ូន ហេង	ប	២៣.៩.៦៨	-	ទ្រឹស្តីសេដ្ឋកិច្ច	-	-

៥—ក្រសួងផែនការចំនួន ០១ នាក់

ក— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០១ នាក់

៧៤	ហ៊ិន គិមសាន	ប	១១.៧.៦៨	-	សេដ្ឋកិច្ច ស្ថិតិ	៩០ខI.១	១

៦—ក្រសួងយុត្តិធម៌ចំនួន ០៦ នាក់

ក— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០៦ នាក់

៧៥	ហ៊ាន វិទូ	ប	១១.៩.៦៩	-	និតិសាស្ត្រ	៩០ខI.១	១
៧៦	យូរ ឧត្តរា	ប	១២.៦.៧០	-	—	-	-
៧៧	សុខ កល្យាណ	ប	០១.០១.៧១	-	—	-	-
៧៨	អ៊ឹម សុផាន	ប	០៦.៤.៦៨	-	—	-	-
៧៩	និន ស៊ីវុទ្ធី	ប	១១.៩.៦៩	-	—	-	-
៨០	គីក សុវណ្ណារ៉េត	ប	២៥.៨.៦៧	-	—	-	-

៧—ក្រសួងសុខាភិបាលចំនួន ០៥ នាក់

ក— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០៤ នាក់

៨១	សុខ បញ្ញា	ប	១៧.១១.៦៥	-	វេជ្ជសាស្ត្រទូទៅ	៩០ខI.១	១
៨២	ម៉ុម ច័ន្ទតារា	ប	១៨.៨.៦៩	-	អតិសុខុមប្រាណ សាស្ត្រ ជីវវិទ្យា	-	-
៨៣	ហង្ស ប៊ុនថារតន៍	ប	០៧.៤.៦៩	-	ឱសថសាស្ត្រ	-	៤
៨៤	ព្រាប ឡឺ	ប	០៤.៩.៦៧	-	វេជ្ជសាស្ត្រទូទៅ	-	៧

ខ— អ្នកបច្ចេកទេសថ្នាក់ពាក់កណ្ដាលឧត្តមចំនួន ០១ នាក់

៨៥	ប៊ួយ ស៊ីណាត	ប	១១.១០.៦៩	-	ឆ្មប	៩០ខII.១	៦

៨—ក្រសួងទេសចរណ៍ចំនួន ០១ នាក់

ក— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០១ នាក់

៨៦	ប៉ូច វរលក្ខណ៍	ស	០៦.៥.៧១	-	ភាសានិងអក្សរសិល្ប៍ រុស្ស៊ីនិងភាសាអង់គ្លេស	៩០ខI.១	១

៩—ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចំនួន ០៥ នាក់

ក— អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រចំនួន ០១ នាក់

៨៧	សារ សំបូរ	ស	១៤.៤.៦៤	-	សេដ្ឋកិច្ច	៩០ខI.៤	៣

ខ— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០៤ នាក់

[illegible]	ហៃន សម្បត្តិ	ប	៧.០២.៦៨	-	សេដ្ឋកិច្ច	៩០ឱ.១	១
[illegible]	និក ភូឡាប	ស	១៦.០១.៦៩	-	គណនេយ្យ	-	-
[illegible]	លី សែ	ប	០៨.៥.៦៦	-	ហិរញ្ញវត្ថុនិងគណនេយ្យ	ឱ.១	-
[illegible]	ប៊ុន បណ្ឌិទ្ធ	ប	២៦.០២.៦៤	-	សេដ្ឋកិច្ចជាតិ	៩០ឱ.១	២

១០—ក្រសួងពាណិជ្ជកម្មចំនួន ០២ នាក់

ក— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០២ នាក់

[illegible]	ថេត ប្រណិត	ប	២០.១០.៧០	-	សេដ្ឋកិច្ចពាណិជ្ជកម្ម	៩០ឱ.១	១
[illegible]	និន សុមល្លីវង្ស	ប	១៩.០១.៦៧	-	—	-	-

១១—ទីស្ដីការគណៈរដ្ឋមន្ត្រីចំនួន ០១ នាក់

ក— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០១ នាក់

[illegible]	ដាញ់ ដារិទ្ធ	ប	០៣.៥.៧២	---	សេ.កិច្ចមិសាស្ត្រ	៩០ឱ.១	៦

១២—អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជាចំនួន ០១ នាក់

ក— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០១ នាក់

[illegible]	ណាន ដានី	ប	០១.០២.៦៦	-	សេដ្ឋកិច្ចនិងការគ្រប់គ្រងផ្នែកដឹកជញ្ជូន	ឱ.១	១

១៣—ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ចំនួន ០១ នាក់

ក— អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០១ នាក់

[illegible]	ដួង មាសដារី	ប	១៧.៤.៧០	-	ប.ទេសអេឡិចត្រូនិច	៩០ឱ.១	១
[illegible]	សួរ ច្ចាតុង	ប	២៨.៨.៧១	-	ភាសានិងអក្សរសិល្ប៍រុស្ស៊ីនិងអង់គ្លេស	ឱ.១	១

កំណត់សំគាល់

-ប្រទេសរុស្ស៊ី

-ប្រទេសអាល្លឺម៉ង់

-ប្រទេសវៀតណាម

-ប្រទេសហុងគ្រី

-ប្រទេសឆេក្ង

-ប្រទេសប៊ុលហ្គារី

-ប្រទេសម៉ុងហ្គោលី

បានបញ្ឈប់បញ្ជីត្រឹមចំនួន ៩៧ នាក់

« កៅសិបប្រាំពីរនាក់ » ប៉ុណ្ណោះ ។

ភ្នំពេញ, ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៥

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ឡោក់ សុខ

បោះពុម្ពនៅរោងពុម្ពទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តំលៃ ៨៦៨ រៀល